នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jan-2013, 15:29
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើតាមដានរបស់សហព្រះរាជអាជ្ញា សុំដាក់នៅក្នុងសំណុំរឿងនូវខ្សែវីដេអូនៃបទសម្ភាសន៍ របស់សាក្សីជំនាញ PHILIP SHORT

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS

លោក គង់ សំអុន
លោក Arthur VERCKEN
លោកស្រី Anta GUISSE
លោក Jacques VERGÈS

# សំណើ និងប្រវត្តិនីតិវិធី

១- នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១២ ដោយអនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក សហព្រះរាជអាជ្ញាបានស្នើសុំការអនុញ្ញាតដាក់ទៅក្នុងសំណុំរឿង នូវខ្សែអាត់សម្លេងនៃបាឋកថា (“បាឋកថា”) ដែលបានផ្ដល់ជូនដោយសាក្សីជំនាញ Philip Short នៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៥ នៅមជ្ឈមណ្ឌលសិក្សាអាស៊ីអាគ្នេយ៍នៃសាកលវិទ្យាល័យកាលីហ្វូញ៉ា, ឡូសអែងហ្គែលឡេស (Centre for South East Asian Studies of the University of California, Los Angeles) (“សំណើ”)[1]។ សហព្រះរាជអាជ្ញាក៏ស្នើសុំការអនុញ្ញាត ដើម្បីចាក់សម្រង់សង្ខេបនៃខ្សែវីឌីអូនៃបាឋកថានោះផងដែរ ដែលពេលនោះគេអាចរកបាននៅលើគេហទំព័រប៉ុណ្ណោះ គឺក្នុងពេលនៃការផ្ដល់សក្ខីកម្មរបស់អ្នកជំនាញ[2]។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ អង្គជំនុំជម្រះបានអនុញ្ញាតតាមការស្នើសុំនេះ[3]។

២- បន្ទាប់ពីដាក់សំណើនេះ សហព្រះរាជអាជ្ញាមានលទ្ធភាពទទួលបាននូវខ្សែវីឌីអូចំនួនមួយច្បាប់នៃការធ្វើបាឋកថា។ អនុលោមតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះលើសំណើនេះ សហព្រះរាជអាជ្ញាស្នើសុំការអនុញ្ញាត ដើម្បីដាក់ខ្សែវីឌីអូនេះបញ្ចូលទៅក្នុងសំណុំរឿង។ ដោយហេតុថា អង្គជំនុំជម្រះបានអនុញ្ញាតរួចហើយ ឲ្យប្រើប្រាស់ខ្សែវីដេអូនេះនៅក្នុងអម្លុងពេលនៃការសួរដេញដោលចំពោះសាក្សីជំនាញរូបនេះ សហព្រះរាជអាជ្ញាជូនជាយោបល់ថា ការដាក់បញ្ចូលខ្សែវីដេអូនេះនៅក្នុងសំណុំរឿងនឹងបានជាប្រយោជន៍ដល់យុត្តិធម៌។ ការណ៍នេះអាចបើកឲ្យដល់គ្រប់ភាគីនូវឱកាសស្មើៗគ្នា ក្នុងការប្រើប្រាស់នូវខ្សែវីឌីអូនេះ (ទាំងនៅពេលមុន និងទាំងនៅក្នុងពេលកំពុងសួរដេញដោល) និងបង្កើតនូវកំណត់ហេតុឲ្យបានកាន់តែគ្រប់សព្វថែមទៀត អំពីភ័ស្តុតាងរបស់លោក Short នៅក្នុងសំណុំរឿង។

---

[1] **E230** សំណើរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨៧(៤) ស្នើសុំដាក់ក្នុងសំណុំរឿងនូវខ្សែអាត់សម្លេងនៃបាឋកថាមួយរបស់អ្នកជំនាញ Philip Short និងសុំប្រើប្រាស់ខ្សែវីដេអូនៃបាឋកថានេះ ក្នុងអំឡុងពេលសួរដេញដោល អ្នកជំនាញ, ១៧ កញ្ញា ២០១២, ត្រង់កថាខណ្ឌទី១។

[2] *ដដែលដូចមុន* ត្រង់កថាខណ្ឌទី២។

[3] **E260** ចម្លើយតបទៅនឹងសំណើតាមវិធាន៨៧.៤ សុំដាក់ឯកសារថ្មីៗចូលក្នុងសំណុំរឿង ពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សីលោក Francois PONCHAUD និងលោក Sydney SCHANBERG (E243) ព្រមទាំងអ្នកជំនាញ លោក Philip Short (E226, 226/1 និង 230) និងលោកស្រី Elizabeth BECKER (E232 និង E232/1)”, ១៨ មករា ២០១៣, ត្រង់កថាខណ្ឌទី៦។

អាចលុបបំបាត់ផងដែរនូវការប្រថុយប្រថានចំពោះការលំបាកផ្សេងៗផ្នែកបច្ចេកទេស ដែលនឹងអាចកើតមានឡើង ប្រសិនជាខ្សែវីឌីអូនេះចូលមើលបាន ដោយការប្រើប្រាស់តាមប្រព័ន្ធពីចម្ងាយ តាមរយៈអ៊ីនធ័រណែត នៅក្នុងអម្លុងពេលដែលលោក Short ផ្តល់សក្ខីកម្ម។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY សហព្រះរាជអាជ្ញា | | [signature] |